**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៤៥ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការគ្រប់គ្រងមន្ទីរពិសោធន៍សិក្សាសហគមន៍**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៨៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការជ្រើសរើសការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សានៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍នៅតាមរដ្ឋបាលឃុំ សង្កាត់ប្រកបដោយគុណភាព ប្រសិទ្ធភាព និងនិរន្តរភាព ដើម្បីផ្តល់ឱកាសឱ្យកុមារដែលមានអាយុចាប់ពី៣(បី)ឆ្នាំដល់ក្រោម៦(ប្រាំមួយ)ឆ្នាំ ទទួលបានសេវាអប់រំប្រកបដោយសមធម៌និងបរិយាបន្ន។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពី៖

- ស្តង់ដាអប្បបរមារបស់មត្តេយ្យសិក្សាសហគមន៍

- ធនធាននានាដើម្បីគាំទ្រដល់កិច្ចដំណើរការនិងការអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍។

**មាត្រា៣ ..**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមត្តេយ្យសិក្សាសហគមន៍ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលឃុំ សង្កាត់។

**មាត្រា៤ ..**

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

មត្តេយ្យសិក្សាសហគមន៍ : សំដៅដល់មណ្ឌលឬថ្នាក់មត្តេយ្យសិក្សានៅតាមឃុំ សង្កាត់ ដែលបង្កើតឡើងដោយរដ្ឋបាលឃុំ សង្កាត់ ដោយប្រើប្រាស់នូវមូលនិធិរបស់ឃុំ សង្កាត់ ឬបានទទួលការគាំទ្រពីដៃគូអភិវឌ្ឍ ឬសប្បុរសជននានា។

ដៃគូអភិវឌ្ឍ : សំដៅដល់នីតិបុគ្គល រូបវន្តបុគ្គល អង្គការ ឬសមាគម ដែលបានចុះអនុស្សរណៈស្តីពីការយោគយល់ច្បាស់លាស់ជាមួយតំណាងរាជរដ្ឋាភិបាល ដោយមានកំណត់ចក្ខុវិស័យ ផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងកម្មវិធីឧបត្ថម្ភគាំទ្រដល់មត្តេយ្យសិក្សាសហគមន៍។

សប្បុរសជន : សំដៅដល់បុគ្គល បព្វជិត គ្រួសារ សហគមន៍ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលជួយឧបត្ថម្ភដល់មត្តេយ្យសិក្សាសហគមន៍ដោយពុំមានផែនការជាក់លាក់ក្នុងការជួយឧបត្ថម្ភ ឬពុំមានចុះអនុស្សរណៈស្តីពីការយោគយល់ច្បាស់លាស់ជាមួយរដ្ឋបាលថ្នាក់ជាតិឬរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយ។

## ជំពូកទី២
## ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍

### ផ្នែកទី១
### ការបង្កើត ការបិទ និងការដាក់បញ្ចូលជាឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ

**មាត្រា៥ ..**

ក្រុមប្រឹក្សាឃុំ សង្កាត់ មានសិទ្ធិបង្កើតឬបិទថ្នាក់មត្តេយ្យសិក្សាសហគមន៍ដោយផ្អែកលើស្ថិតិកុមារអាយុពី៣(បី)ឆ្នាំដល់ក្រោម៦(ប្រាំមួយ)ឆ្នាំ និងផ្អែកលើស្ថានភាពនៃការផ្តល់សេវាអប់រំនៅក្នុងមូលដ្ឋានរបស់ខ្លួន។

ការបង្កើតឬការបិទមត្តេយ្យសិក្សាសហគមន៍ ត្រូវកំណត់ដោយដីការបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

រដ្ឋបាលឃុំ សង្កាត់ អាចប្រើប្រាស់មូលនិធិរបស់ខ្លួនសម្រាប់រៀបចំដំណើរការមត្តេយ្យសិក្សាសហគមន៍។

**មាត្រា៦ ..**

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានគម្រោងបង្កើតមត្តេយ្យសិក្សាសហគមន៍ថ្មីត្រូវធានាលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

- ទីតាំងមត្តេយ្យសិក្សាសហគមន៍ ត្រូវស្ថិតនៅតំបន់ដែលឆ្ងាយពីសាលា/ថ្នាក់មត្តេយ្យសិក្សារដ្ឋឬស្ថិតនៅតំបន់ជួបការលំបាកសម្រាប់កុមារតូចក្នុងការទទួលបានសេវាអប់រំ
- ទីតាំងមត្តេយ្យសិក្សាសហគមន៍ ត្រូវមានទីធ្លាសមស្រប មានអនាម័យ មានសុវត្ថិភាព មានបង្គន់និងទឹកស្អាតសម្រាប់ប្រើប្រាស់ មានកន្លែងលាងដៃបំពាក់សម្ភារៈបរិក្ខារ និងធនធានសិក្សា និងមានកន្លែងនិងសម្ភារៈសម្រាប់កុមារលេងក្រៅថ្នាក់យ៉ាងតិចមួយប្រភេទដែលកុមារអាចលេងបានជាប្រចាំ។

**មាត្រា៧ ..**

ក្រុមប្រឹក្សាឃុំ សង្កាត់ មានសិទ្ធិស្នើដាក់បញ្ចូលថ្នាក់មត្តេយ្យសិក្សាសហគមន៍ទៅជាឧបសម្ព័ន្ធគ្រឹះស្ថានសិក្សាសាធារណៈណាមួយ ដោយផ្អែកលើលក្ខណសម្បត្តិនិងស្ថានភាពជាក់ស្ដែងនៅក្នុងមូលដ្ឋាន។

លក្ខណសម្បត្តិសម្រាប់ប្រែក្លាយថ្នាក់មត្តេយ្យសិក្សាសហគមន៍ជាឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈណាមួយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

## ផ្នែកទី២
## ដំណើរការមត្តេយ្យសិក្សាសហគមន៍

**មាត្រា៨ ..**

ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានបង្កើតថ្នាក់មត្តេយ្យសិក្សាសហគមន៍នៅក្នុងមូលដ្ឋានរបស់ខ្លួន មានតួនាទីនិងភារកិច្ចដឹកនាំនិងអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍ដូចតទៅ៖

- រៀបចំផែនការសកម្មភាពនិងថវិកាសម្រាប់អភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍ ដោយដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគបីឆ្នាំរបស់ខ្លួន
- គ្រប់គ្រងនិងចាត់ចែងថវិកាសម្រាប់ដំណើរការមត្តេយ្យសិក្សាសហគមន៍
- កំណត់ជ្រើសរើសទីតាំងសម្រាប់បង្កើតមត្តេយ្យសិក្សាសហគមន៍
- កៀរគរធនធានសម្រាប់អភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍
- ត្រួតពិនិត្យតាមដានដំណើរការមត្តេយ្យសិក្សាសហគមន៍

- ជ្រើសរើសនិងចុះកិច្ចសន្យាជាមួយគ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- កំណត់គោលការណ៍លើកទឹកចិត្តគ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍
- រៀបចំប្រជុំនិងធ្វើរបាយការណ៍ការងារតាមកាលកំណត់ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡា។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍នីមួយៗ ដើម្បីសម្របសម្រួលការងារគ្រប់គ្រងដំណើរការមត្តេយ្យសិក្សាសហគមន៍ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ សមាសភាពនិងតួនាទីភារកិច្ចជាក់ស្តែងនៃគណៈកម្មការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់។

**មាត្រា៩ ..**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវកំណត់យន្តការ នីតិវិធី និងលក្ខខណ្ឌនៃការជ្រើសរើសគ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំផែនការនិងផ្តល់ការបណ្តុះបណ្តាលនិងបំប៉នតាមស្តង់ដា អំពីការងារបច្ចេកទេសបង្រៀននិងការងារគ្រប់គ្រងរដ្ឋបាលថ្នាក់រៀន ជូនគ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍និងអ្នកពាក់ព័ន្ធ។

## ផ្នែកទី៣
## ការគាំទ្រដល់មត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា

**មាត្រា១០ ..**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវដាក់បញ្ចូលកម្មវិធីអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍នៅក្នុងគោលនយោបាយអាទិភាពរបស់ក្រសួង។

**មាត្រា១១ ..**

មត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ត្រូវមានសិទ្ធិទទួលបានការវាយតម្លៃដើម្បីទទួលថវិកាគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា។

ស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា១២ ..**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបង្កើតក្រុមការងារដែលមានសមាសភាពមកពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈ

សម្រាប់វាយតម្លៃមត្តេយ្យសិក្សាសហគមន៍ ដើម្បីផ្តល់ការទទួលស្គាល់ជាមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា។

លទ្ធផលនៃការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ដើម្បីផ្តល់ការទទួលស្គាល់ជាមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ត្រូវផ្សព្វផ្សាយជាសាធារណៈ និងដាក់ឱ្យអនុវត្តដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

បែបបទនិងនីតិវិធីនៃការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ដើម្បីផ្តល់ការទទួលស្គាល់ជាមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា១៣ ..**

មត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ត្រូវទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែដល់គ្រូបង្រៀនចំនួន៦០០ ០០០(ប្រាំមួយសែន)រៀលក្នុងមួយនាក់ក្នុងមួយខែ និងត្រូវទទួលបានស្របតាមកិច្ចសន្យា។

ការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូនដល់គ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍តាមឆ្នាំនីមួយៗ ត្រូវអនុវត្តស្របតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

ក្រុមប្រឹក្សាឃុំ សង្កាត់ អាចផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមជូនដល់គ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ទៅតាមលទ្ធភាពរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ។

**មាត្រា១៤ ..**

មត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ត្រូវទទួលបានថវិកាប្រចាំឆ្នាំពីក្រសួងអប់រំ យុវជន និងកីឡា សម្រាប់កិច្ចដំណើរការនិងការអភិវឌ្ឍ។ គោលការណ៍និងអត្រានៃការឧបត្ថម្ភត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា១៥ ..**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវគ្រោងថវិកាគាំទ្រមត្តេយ្យសិក្សាសហគមន៍ដែលទទួលបានការវាយតម្លៃនិងប្រកាសទទួលស្គាល់ជាមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា។

**មាត្រា១៦ ..**

ថវិកាដំណើរការនិងកិច្ចអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍ ត្រូវប្រើប្រាស់តាមមុខចំណាយដូចខាងក្រោម៖

- ការប្រជុំបច្ចេកទេស
- សម្ភារៈឧបទេស
- ចំណាយសម្រាប់ទឹកស្អាតនិងអនាម័យ
- ចំណាយផ្សេងៗ។

ចំណាយលើការជួសជុលនិងការកែលម្អបរិស្ថានមត្តេយ្យសិក្សាសហគមន៍ ជាបន្ទុករបស់រដ្ឋបាលឃុំ សង្កាត់។

**មាត្រា១៧ ..**

នីតិវិធីបើកផ្តល់និងទូទាត់ថវិកាឧបត្ថម្ភប្រចាំខែជូនគ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ ថវិកាសម្រាប់កុមារ និងថវិកាដំណើរការនិងកិច្ចអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៨ ..**

មត្តេយ្យសិក្សាសហគមន៍ដែលបានបង្កើតនិងកំពុងដំណើរការក្រោមកម្មវិធីឧបត្ថម្ភរបស់ដៃគូអភិវឌ្ឍត្រូវបានទទួលការវាយតម្លៃ ដើម្បីផ្តល់ការទទួលស្គាល់ជាមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា លុះត្រាតែដៃគូអភិវឌ្ឍបញ្ចប់កម្មវិធីឧបត្ថម្ភ។

ករណីដែលមត្តេយ្យសិក្សាសហគមន៍មិនបានទទួលស្គាល់ជាមត្តេយ្យសិក្សាសហគមន៍ដែលមានស្តង់ដា រដ្ឋបាលឃុំ សង្កាត់ អាចប្រើប្រាស់មូលនិធិរបស់ខ្លួន ដើម្បីបន្តនិរន្តរភាពរបស់មត្តេយ្យសិក្សាសហគមន៍ក្រោយពីដៃគូអភិវឌ្ឍបញ្ចប់កម្មវិធីឧបត្ថម្ភ។

## ជំពូកទី៣
## ការពិនិត្យតាមដាននិងការវាយតម្លៃ

**មាត្រា១៩ ..**

ក្រសួងអប់រំ យុវជន និងកីឡានិងក្រសួងពាក់ព័ន្ធ ត្រូវរៀបចំយន្តការពិនិត្យតាមដាន វាយតម្លៃលទ្ធផលបំពេញការងារ និងមានវិធានការគាំទ្រមត្តេយ្យសិក្សាសហគមន៍។

**មាត្រា២០ ..**

ថវិកាសរុបដែលត្រូវផ្តល់ដល់មត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដាត្រូវកំណត់ក្នុងទំហំដែលត្រូវបានវិភាជរួចហើយក្នុងថវិកាក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ២០១៨។ សម្រាប់ឆ្នាំបន្តបន្ទាប់ត្រូវផ្តល់ជូនដោយផ្អែកលើវឌ្ឍនភាពនៃមត្តេយ្យសិក្សាសហគមន៍និងលទ្ធភាព ថវិកា។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា២១ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៤កើត ខែ មិគសិរ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

| | | |
|---|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ** | **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា** |
| **សម្តេចក្រឡាហោម ស ខេង** | **អូន ព័ន្ធមុនីរ័ត្ន** | **ហង់ ជួន ណារ៉ុន** |

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ